**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ    ក្រសួងបរិស្ថាន    អង្គការសត្វព្រៃ និងរុក្ខជាតិ

# សេចក្តីប្រកាសព័ត៌មានស្តីពី
# ការរកឃើញការបង្កកំណើតរបស់ផ្កាថ្ម ជាលើកទី២ នៅសមុទ្រកម្ពុជា

អង្គការសត្វព្រៃ និងរុក្ខជាតិប្រចាំកម្ពុជា សហការជាមួយ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការគាំទ្រពី Bubbles Up Dive Centre, Khmer Dive Group និងមូលនិធិសង្សារ បានបន្តធ្វើការសិក្សាស្រាវជ្រាវអំពីការបង្កកំណើតរបស់ផ្កាថ្មប៉ប្រះទឹក នៅប្រជុំកោះរ៉ុងនៃប្រទេសកម្ពុជា នៅក្នុងអំឡុងខែកុម្ភៈ និងខែមីនា ឆ្នាំ២០២៥ តាមការព្យាករណ៍ថាជារដូវបង្កកំណើតរបស់ផ្កាថ្ម។

នេះជាឆ្នាំទី២ហើយដែលក្រុមការងារចុះស្រាវជ្រាវអំពីការបង្កកំណើតរបស់ផ្កាថ្មនៅសមុទ្រកម្ពុជា បន្ទាប់ពីបានរកឃើញជាលើកដំបូងនៅឆ្នាំ២០២៤ ហើយត្រូវបានរកឃើញសារជាថ្មីម្តងទៀតនៅក្នុងឆ្នាំ២០២៥។ ការរកឃើញការបង្កកំណើតផ្កាថ្មជាលើកទី២ នៅក្នុងឆ្នាំ២០២៥នេះ បានបង្ហាញពីភាពជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងអភិរក្សរួមគ្នារបស់ក្រសួង ស្ថាប័ន អាជ្ញាធរ និងអង្គការពាក់ព័ន្ធ ដែលបង្កលក្ខណៈអំណោយផលដល់ការរស់រានមានជីវិតរបស់ផ្កាថ្មប៉ប្រះទឹកនៅប្រជុំកោះរ៉ុង ជួយឱ្យផ្កាថ្មមានភាពធន់ និងមានសុខភាពល្អ បើទោះបីជាផ្កាថ្មនៅតំបន់នេះ ធ្លាប់ទទួលរងផលប៉ះពាល់ពីព្រឹត្តិការណ៍នៃផ្កាថ្មប្រែពណ៌ស (Coral Bleaching Event) ក្នុងឆ្នាំ២០២៤ ក៏ដោយ។

ក្រុមការងារកំពុងបន្តតាមដានសុខភាព និងស្ថានភាពនៃផ្កាថ្ម នៅក្នុងដែនសមុទ្រកម្ពុជាយ៉ាងយកចិត្តដាក់ដើម្បីយល់ដឹងនិងកត់ត្រាទិន្នន័យអំពីការបង្កកំណើតរបស់ផ្កាថ្ម ដើម្បីជាទុនក្នុងការតាមដានដំណើរការនៃការបន្តពូជ និងការរស់រានមានជីវិតរបស់ផ្កាថ្មនៅក្នុងតំបន់។

កញ្ញា **Jun Cheng ប្រធានគ្រប់គ្រងជាន់ខ្ពស់នៃកម្មវិធីអភិរក្សតំបន់ឆ្នេរ និងសមុទ្រប្រចាំអង្គការសត្វព្រៃ និងរុក្ខជាតិប្រចាំកម្ពុជា** មានប្រសាសន៍ថា ៖ "យើងពិតជារីករាយខ្លាំងណាស់ដែលបានឃើញការបង្កកំណើតរបស់ផ្កាថ្មជាលើកទី២នៅប្រជុំកោះរ៉ុង។ ការរកឃើញនេះបង្ហាញពីសារៈសំខាន់នៃកិច្ចសហការរួមគ្នានៃការងារអភិរក្ស និងសារសំខាន់ក្នុងការបន្តការពារប្រព័ន្ធអេកូឡូស៊ីដ៏សំខាន់ទាំងនេះ។"

ឯកឧត្តម **ឌិត ទីណា** **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** មានប្រសាសន៍ថា៖ "ការបង្កកំណើតផ្កាថ្មនៅក្នុងដែនសមុទ្ររបស់កម្ពុជា ដែលរកឃើញ២ឆ្នាំជាប់ៗគ្នា ឆ្លុះបញ្ចាំងឱ្យឃើញថា គេ្យតបរិស្ថានរបស់យើងមានលក្ខណៈអំណោយផលដល់ផ្កាថ្ម ឱ្យរស់រានមានជីវិត មានសុខភាពល្អ និងអាចបង្កកំណើតបានថែមទៀត។ បាតុភូតដ៏សំខាន់នេះ សម្រេចបានដោយសារការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័ន ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនានាជាសេនាធិការ ដើម្បីការពារធនធានជលផលបាតសមុទ្រនៅកម្ពុជាឱ្យមាននិរន្តរភាព។"

ឯកឧត្តមបណ្ឌិត **អ៊ាង សុផល្លែត** **រដ្ឋមន្ត្រីក្រសួងបរិស្ថាន** បានមានប្រសាសន៍ថា៖ "ការបង្កកំណើតផ្កាថ្មនៅក្នុងដែនសមុទ្ររបស់កម្ពុជា ដែលបានរកឃើញជាប់ៗគ្នា២ឆ្នាំបន្តបន្ទាប់នេះ ជាសញ្ញាដ៏ល្អដែលបញ្ជាក់ថា សភាពបរិស្ថានសមុទ្រនៅកម្ពុជា កំពុងតែមានស្ថានភាពប្រសើរឡើង និងមានសុខភាពល្អ ខណៈមានការពង្រឹងសកម្មភាពអភិរក្ស និងការត្រួតពិនិត្យសកម្មភាពដែលប៉ះពាល់បរិស្ថានសមុទ្រ។ ការអភិរក្សផ្កាថ្ម និងការបន្តពូជផ្កាថ្ម ជាសកម្មភាពដ៏សំខាន់ក្នុងការការពារបរិស្ថានសមុទ្រ ដោយផ្កាថ្មមានតួនាទីសំខាន់ក្នុងការការពារប្រព័ន្ធអេកូស៊ីសមុទ្រ ជម្រកសត្វសមុទ្រ បង្កើនតម្លៃសេដ្ឋកិច្ចតាមរយៈទេសចរណ៍ និងនិរន្តភាពនៃការនេសាទ។ នេះបង្ហាញពីជោគជ័យនៃការអភិរក្សធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថានយ៉ាងមានប្រសិទ្ធភាព ក្រោមការដឹកនាំរបស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា ព្រមទាំងការចូលរួមយ៉ាងសកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធទាំងអស់ដែលជាសេនាធិការ អនុវត្តយុទ្ធសាស្ត្រអភិរក្ស និងអភិវឌ្ឍន៍បរិស្ថានតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។"

អង្គការសត្វព្រៃ និងរុក្ខជាតិប្រចាំកម្ពុជា ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តសិក្សា និងចងក្រងឯកសារអំពីការរកឃើញនេះ ដើម្បីយល់ដឹងកាន់តែច្បាស់អំពីកត្តាដែលរួមចំណែកដល់ការបង្កកំណើតផ្កាថ្មប្រកបដោយជោគជ័យ និងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនៃការងារអភិរក្ស។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនសាធារណជនជ្រាបជាព័ត៌មាន៕

**កំណត់ចំណាំសម្រាប់អ្នកសារព័ត៌មាន**

*សូមចុចលើ[តំណភ្ជាប់]ដើម្បីទាញយករូបភាព*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង**


**កញ្ញា ហែម ម៉ានីតា** មន្ត្រីទំនាក់ទំនង នៃអង្គការសត្វព្រៃ និងរុក្ខជាតិប្រចាំកម្ពុជា

**+៨៥៥ ៩៧ ៥ ៧០៣ ៧៧០**

hem.manita@fauna-flora.org

**លោក** អ៊ុក វិបុល ប្រធាននាយកដ្ឋានអភិរក្សជលផល នៃរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**+៨៥៥ ១២ ៩០៨១២១**


ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥